ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ៦១២ អយក.សណន

# សេចក្តីណែនាំ
# ស្តីពី
# ការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍ សម្រាប់ឆ្នាំសិក្សា២០២៤-២០២៥

ដើម្បីជានាដល់ការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍ប្រកបដោយគុណភាព និងប្រសិទ្ធភាព ក្រសួងសូមធ្វើការណែនាំបន្ថែមលើសេចក្តីណែនាំលេខ៥៥៤ អយក. សណន. ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៤ ជូនមន្ទីរអប់រំ យុវជននិងកីឡាខេត្ត ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក រដ្ឋបាលឃុំ សង្កាត់ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈគោលដៅ ដែលមានកម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍ ដូចខាងក្រោម៖

## ១. រយៈពេលផ្តល់អាហារដល់សិស្ស

ក)ឆ្នាំសិក្សា២០២៤-២០២៥ ត្រូវចាប់ផ្តើមដំណើរការចម្អិននៅថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២៤ និងបញ្ចប់ទៅវិញនៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២៥ ដោយត្រូវអនុវត្តដូចខាងក្រោម៖

- ដំណាក់កាលទី១៖ដំណើរការចម្អិននៅដើមឆ្នាំសិក្សាថ្មី ចាប់ពីថ្ងៃទី៤ ខែវិច្ឆិកា ដល់ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៤ មានរយៈពេលចម្អិនអប្បបរមា ៣០(សាមសិប)ពេល ដោយប្រើប្រាស់ថវិកាឆ្នាំ២០២៤
- ដំណាក់កាលទី២៖បន្តដំណើរការចម្អិនចាប់ពីថ្ងៃទី៣ ខែមករា ដល់ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២៥ មានរយៈពេលចម្អិនអប្បបរមា ១៥៤(មួយរយហាសិបបួន)ថ្ងៃ ដោយប្រើប្រាស់ថវិកាឆ្នាំ២០២៥

ខ)ដើមឆ្នាំសិក្សា២០២៥-២០២៦ ត្រូវចាប់ផ្តើមដំណើរការចម្អិននៅខែតុលា រហូតដល់ខែធ្នូ ឆ្នាំ២០២៥ និងមានរយៈពេលចម្អិនអប្បបរមា ៥៦(ហាសិបប្រាំមួយ)ថ្ងៃ ដោយប្រើប្រាស់ថវិកាឆ្នាំ២០២៥។

## ២. មុនពេលដំណើរការឆ្នាំសិក្សា២០២៤-២០២៥

- ធ្វើបច្ចុប្បន្នកម្មនិងកែសម្រួលសមាសភាពគណៈកម្មការដឹកនាំនិងគ្រប់គ្រងចំពោះកិច្ចការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀន ដូចមានចែងក្នុងប្រកាសលេខ១១៧៣ អយក.ប្រក ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៤ ចាប់ពីថ្នាក់ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ និងសាលារៀន។
- ធ្វើស្វ័យប្រកាសក្នុងគ្រឹះស្ថានសិក្សារបស់ខ្លួន អំពីចំនួនបុគ្គលិក ថ្នាក់រៀនតាមវេន សិស្ស(គិតបញ្ចូលទាំងសិស្សថ្នាក់មត្តេយ្យសិក្សា និង/ឬសាលាមត្តេយ្យសិក្សាមានទីតាំងក្នុងបរិវេណគ្រឹះស្ថានសិក្សាខ្លួន) សិស្សហូបអាហារតាមវេន ការបង្រៀននិងរៀនមួយវេន ឬពេញមួយថ្ងៃ ចំនួនចុងភៅ និងចំនួនថ្ងៃចម្អិនអប្បបរមា ស្របតាមប្រកាសលេខ៥០៧សហវ.ប្រក.អកគ.។
- បន្តកិច្ចសន្យាជាមួយអ្នកផ្គត់ផ្គង់ស្បៀងមានស្រាប់ឱ្យផ្គត់ផ្គង់ស្បៀងរហូតដល់ថ្ងៃទី២៧ខែធ្នូឆ្នាំ២០២៤ និងរៀបចំនីតិវិធីជ្រើសរើសអ្នកផ្គត់ផ្គង់ស្បៀងថ្មី ដើម្បីផ្គត់ផ្គង់ពីថ្ងៃទី៣ ខែមករា រហូតដល់ថ្ងៃទី២៧


អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

ខែធ្នូ ឆ្នាំ២០២៥ ដូចមានណែនាំក្នុងសៀវភៅណែនាំប្រតិបត្តិ។

- ជំរុញនិងលើកទឹកចិត្តដល់សហករណ៍កសិកម្ម ក្រុមអ្នកផលិតនិងកសិករ ឱ្យចូលរួមប្រកួតប្រជែងឱ្យបានច្រើនក្នុងដំណើរការជ្រើសរើសអ្នកផ្គត់ផ្គង់ស្បៀងដោយប្រើប្រាស់ប្រព័ន្ធព័ត៌មានគ្រប់គ្រងកម្មវិធី ធ្វើជាសក្ខីកម្ម និងដើម្បីងាយស្រួលដល់ក្រុមការងារធ្វើការពិនិត្យលទ្ធផលជ្រើសរើសបានទាន់ពេល។
- បន្តកិច្ចសន្យាជាមួយចុងភៅមានស្រាប់ឱ្យដំណើរការចម្អិនរហូតដល់ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៤ និងរៀបចំនីតិវិធីជ្រើសរើសចុងភៅថ្មីសម្រាប់ឆ្នាំសិក្សា២០២៤-២០២៥ តាមចំនួនកំណត់ដូចមានចែងក្នុងកាសលេខ៥០៧សហវ.ប្រក.អកគ. ដោយផ្តល់អាទិភាពដល់ចុងភៅបំពេញការងារល្អកន្លងទៅ។
- កៀរគរធនធានកែលម្អហេដ្ឋារចនាសម្ព័ន្ធ ផ្គត់ផ្គង់សម្ភារៈអនាម័យ សម្ភារៈផ្ទះបាយ និងការផ្តល់អាហារសម្រន់បន្ថែម ដោយសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអ្នកអាណាព្យាបាលសិស្ស។
- ផ្សព្វផ្សាយអំពីសារៈសំខាន់នៃការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍ ក្នុងពេលយុទ្ធនាការប្រមូលកុមារចូលរៀន។

## ៣. ពេលដំណើរការក្នុងសិក្សាឆ្នាំសិក្សា២០២៤-២០២៥

បន្ទាប់ពីថ្ងៃបើកបវេសនកាលឆ្នាំសិក្សា២០២៤-២០២៥ នៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២៤ កម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍ ត្រូវដំណើរការចម្អិនអាហារជូនសិស្ស ចាប់ពីថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២៤។ ដើម្បីធានាបានសង្គតិភាព និងប្រសិទ្ធភាព ត្រូវអនុវត្តដូចខាងក្រោម៖

### ៣.១ ការរៀបចំចម្អិននិងផ្តល់អាហារជូនសិស្ស

គណៈកម្មការដឹកនាំនិងគ្រប់គ្រងចំពោះកិច្ចការអនុវត្តកម្មវិធីថ្នាក់សាលារៀន និងអ្នកពាក់ព័ន្ធ ត្រូវ៖

- គ្រប់គ្រងស្ថិតិសិស្ស ចុងភៅ ហេដ្ឋារចនាសម្ពន្ធ សម្ភារៈអនាម័យ និងសម្ភារៈផ្ទះបាយ ឱ្យបានត្រឹមត្រូវដោយបញ្ចូលក្នុងប្រព័ន្ធព័ត៌មានគ្រប់គ្រងកម្មវិធី នៅដើមឆ្នាំសិក្សា។
- ប្រជុំពិភាក្សាជាមួយអ្នកផ្គត់ផ្គង់ស្បៀង ចុងភៅ ក្រុមប្រឹក្សាកុមារ អ្នកអាណាព្យាបាលសិស្ស ដើម្បីកំណត់បញ្ជីមុខម្ហូបប្រចាំសប្តាហ៍ ដោយជ្រើសរើសម្ហូបប្រពៃណី ប្រកបដោយអាហារូបត្ថម្ភចម្រុះ ហើយជាផលិតផលងាយរកបានតាមរដូវកាលនៅក្នុងសហគមន៍ និងមានក្នុងសួនបន្លែសាលារៀន។
- សាលាបឋមសិក្សាគោលដៅនៅក្នុងឃុំ សង្កាត់ ដែលមានអ្នកផ្គត់ផ្គង់ស្បៀងតែម្នាក់ សូមពិចារណាកំណត់បញ្ជីមុខម្ហូបដូចគ្នានៅថ្ងៃចម្អិនដូចគ្នាក្នុងរយៈពេលបីខែម្តង ដើម្បីឱ្យអ្នកផ្គត់ផ្គង់ស្បៀងសហការជាមួយក្រុមកសិករផលិតស្បៀងបានតាមតម្រូវការនិងស្របតាមរដូវកាល។
- ធ្វើគម្រោងបញ្ជីមុខម្ហូប តម្រូវការស្បៀងប្រចាំខែ គិតចំនួនសិស្សហូបអាហារមធ្យមតាមវេនសិក្សាទោះអនុវត្តការបង្រៀននិងរៀនមួយវេន ឬពេញមួយថ្ងៃ ដោយដកចេញចំនួនសិស្សមត្តេយ្យសិក្សារៀងរាល់ថ្ងៃព្រហស្បតិ៍ ឬថ្ងៃគ្រោងមិនចម្អិន ដើម្បីគណនាតម្រូវការស្បៀង និងថវិកាសម្រាប់ធ្វើការបញ្ជាទិញស្បៀងប្រចាំខែទៅអ្នកផ្គត់ផ្គង់ស្បៀង ជៀសវាងលើសថវិកាកម្មវិធីផ្តល់ជូនក្នុងមួយឆ្នាំ។
- កត់ត្រាវត្តមានសិស្សពីបញ្ជីហៅឈ្មោះ បូកសរុបវត្តមានសិស្សជារៀងរាល់ថ្ងៃសិក្សា ដើម្បីប្រើប្រាស់ជាមូលដ្ឋានគិតក្នុងការបញ្ចេញអង្ករ ប្រេងឆា និងអំបិលអ៊ីយ៉ូដសម្រាប់ប្រើប្រាស់នៅថ្ងៃបន្ទាប់។
- ណែនាំសិស្សឱ្យយកចាន ស្លាបព្រា និងដបទឹកមកសាលារៀន ដើម្បីហូបអាហារតាមកាលកំណត់ និងឱ្យអនុវត្តការលាងសម្អាតដៃជាទៀងទាត់ និងការលាងសម្អាតចានបាយ ស្លាបព្រាឱ្យបានស្អាតក្រោយពេលហូបអាហារ។

- ត្រួតពិនិត្យគុណភាព និងបរិមាណស្បៀងឱ្យបានត្រឹមត្រូវ មុនទទួលពីអ្នកផ្គត់ផ្គង់ស្បៀង និងរក្សាទុកក្នុងឃ្លាំងតាមគោលការណ៍ប្រតិបត្តិសុវត្ថិភាពស្បៀង មុននឹងប្រគល់ជូនចុងភៅ។
- ចាត់តាំងគ្រូបង្រៀនឱ្យណែនាំ ពិនិត្យតាមដាន ការអនុវត្តវិធានអនាម័យ និងសុវត្ថិភាពម្ហូបអាហារឱ្យបានខ្ជាប់ខ្ជួនរបស់ចុងភៅ ក្នុងពេលកំពុងនិងក្រោយពេលរៀបចំចម្អិនអាហារនៅផ្ទះបាយសាលារៀនស្របតាមគោលការណ៍ណែនាំរបស់ក្រសួង ដើម្បីធានាថាម្ហូបអាហារដែលចម្អិនរួចមានសុវត្ថិភាព។
- ចាត់ចែងការចែកចាយអាហារដល់សិស្សនៅកន្លែងហូបអាហារ ឬ នៅទីតាំងសមរម្យ ខ្ពស់ផុតពីដីយ៉ាងហោច ៦០ស.ម. ក្រោមការសម្របសម្រួលពីគ្រូបន្ទុកថ្នាក់ និងឬក្រុមប្រឹក្សាកុមារ។
- ធ្វើការទូទាត់ថវិកាជូនដល់អ្នកផ្គត់ផ្គង់ស្បៀង និងចុងភៅឱ្យទាន់ពេល ដោយត្រូវធ្វើឡើងនៅរៀងរាល់ពេលបំណាច់ខែនីមួយៗ តាមកិច្ចសន្យាបានព្រមព្រៀងគ្នា។
- កៀរគរធនធាន ថវិកាមានប្រភពស្របច្បាប់នៅក្នុងសហគមន៍ សប្បុរសជន និងវិស័យឯកជន ដើម្បីគាំទ្រនិងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ព្រមទាំងបិទផ្សាយអំពីចំណូល ចំណាយឱ្យមានតម្លាភាព។
- កត់ត្រាចំណូល ចំណាយក្នុងកិច្ចបញ្ជិកាគណនេយ្យ កិច្ចបញ្ជិកាគណនេយ្យហិរញ្ញកិច្ច(បណ្ណចំណូលចំណាយ បញ្ជីតាមដានសាច់ប្រាក់ក្នុងធនាគារ បញ្ជីបេឡា) គ្រប់គ្រងនិងទុកដាក់ឯកសារហិរញ្ញវត្ថុនិងឯកសារពាក់ព័ន្ធ ឱ្យស្របទៅតាមការណែនាំរបស់កម្មវិធី។
- ធ្វើកំណត់ត្រាស្បៀងប្រចាំថ្ងៃ និងបញ្ចូលទិន្នន័យស្បៀងនិងថវិកាចំណូល ចំណាយ ជារៀងរាល់បំណាច់ខែនីមួយៗ ក្នុងប្រព័ន្ធព័ត៌មានគ្រប់គ្រងកម្មវិធី។ បញ្ចូលទិន្នន័យសិស្ស លទ្ធផលសិក្សាចុងភៅ និងធនធានបានមកពីសហគមន៍ប្រចាំត្រីមាស ក្នុងប្រព័ន្ធព័ត៌មានគ្រប់គ្រងកម្មវិធី ដើម្បីទាញយកធ្វើរបាយការណ៍រីកចម្រើន និងរបាយការណ៍ថវិកាប្រចាំត្រីមាស បានទាន់ពេលវេលា។
- គ្រប់គ្រងបញ្ជីសារពើភណ្ឌពាក់ព័ន្ធនឹងកម្មវិធី រួមមានសម្ភារៈផ្ទះបាយ(ចានបាយសិស្ស ខ្ទះឆ្នាំងបាយ ឆ្នាំងសម្ល វែក) សម្ភារៈបម្រើការចម្អិន និងការរក្សាសុវត្ថិភាពអាហារ (ជ្រុញ កាំបិតកញ្ច្រែង ក្រឡ ធុងក្លាស្សេ ទូទឹកកក) សម្ភារៈក្នុងឃ្លាំងស្បៀង(ជញ្ជីង ទម្រកំណល់ស្បៀង)។
- សហការជាមួយមណ្ឌលសុខភាពផ្តល់ថ្នាំទម្លាក់ព្រូនដល់សិស្ស ណែនាំពីវិធានអនាម័យ និងសុវត្ថិភាពម្ហូបអាហារជូនសិស្សនិងសហគមន៍។ ករណីមានសិស្សពុលអាហារ ត្រូវបញ្ជូនទៅមណ្ឌលសុខភាពដើម្បីសង្គ្រោះ និងរាយការណ៍ទៅអាជ្ញាធរពាក់ព័ន្ធ និងមន្ទីរអប់រំ យុវជន និងកីឡាខេត្ត។
- កំណត់អាណត្តិប្រជុំរបស់គណៈកម្មការដឹកនាំនិងគ្រប់គ្រងចំពោះកិច្ចការអនុវត្តកម្មវិធីថ្នាក់សាលារៀនឱ្យបានច្បាស់លាស់ ដើម្បីពិនិត្យលើវឌ្ឍនភាព ឧបសគ្គ និងរកដំណោះស្រាយឱ្យទាន់ពេលវេលា។
- ចូលរួមការបណ្តុះបណ្តាល អភិវឌ្ឍសមត្ថភាពតាមការចាំបាច់ ដើម្បីឱ្យការអនុវត្តកម្មវិធីបានកាន់តែល្អប្រសើរសម្រាប់ឆ្នាំសិក្សានេះ និងនៅឆ្នាំសិក្សាបន្តបន្ទាប់។

## ៣.២ ការសម្របសម្រួលនិងគាំទ្របច្ចេកទេស

ក. គណៈកម្មការដឹកនាំនិងគ្រប់គ្រងចំពោះកិច្ចការអនុវត្តកម្មវិធីថ្នាក់ឃុំ សង្កាត់ និងអ្នកពាក់ព័ន្ធ ត្រូវៈ

- ណែនាំ សម្របសម្រួលអ្នកពាក់ព័ន្ធក្នុងឃុំ សង្កាត់ និងគ្រឹះស្ថានបឋមសិក្សាគោលដៅ រៀបចំផែនការអភិវឌ្ឍនិងដាក់បញ្ចូលកម្មវិធីផ្តល់អាហារតាមសាលារៀន ក្នុងកម្មវិធីវិនិយោគឃុំ សង្កាត់ កម្មវិធីអភិវឌ្ឍភូមិ និងផែនការប្រតិបត្តិរបស់សាលារៀន។
- សម្របសម្រួលជាមួយអ្នកពាក់ព័ន្ធនៅក្នុងឃុំ សង្កាត់ និងគ្រឹះស្ថានបឋមសិក្សាគោលដៅ ក្នុងការដាក់បញ្ចូលកម្មវិធីផ្តល់អាហារតាមសាលារៀនទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ កម្មវិធីវិនិយោគ៣

ឆ្នាំរំកិលរបស់ឃុំ សង្កាត់ និងផែនការប្រតិបត្តិរបស់សាលារៀន។

- សហការជាមួយនាយកផ្សព្វផ្សាយការជ្រើសរើសអ្នកផ្គត់ផ្គង់ស្បៀង ចុងភៅ តាមគ្រឹះស្ថានបឋមសិក្សាគោលដៅ និងប្រកាសទទួលស្គាល់ជាផ្លូវការដល់ជ័យលាភី នៅក្នុងដែនសមត្ថកិច្ចនៃឃុំ សង្កាត់ខ្លួន។
- ចូលរួមផ្សព្វផ្សាយផែនការថវិកា ការប្រើប្រាស់ថវិកា និងព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីជូនដល់អ្នកពាក់ព័ន្ធនៅក្នុងសហគមន៍។
- ចូលរួមកៀរគរធនធាន ថវិកាពីប្រភពស្របច្បាប់នានា សម្រាប់អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងផ្គត់ផ្គង់សម្ភារៈដែលគាំទ្រដល់ការអនុវត្តកម្មវិធី។
- ចូលរួមអភិវឌ្ឍសមត្ថភាពជាប្រចាំ និងអប់រំណែនាំបន្តជូនដល់គ្រប់ភាគីពាក់ព័ន្ធ ដើម្បីធានាបាននូវប្រសិទ្ធភាព និងនិរន្តភាព នៃការអនុវត្តកម្មវិធី។
- ចូលរួមពិនិត្យ តាមដាន និងលើកកម្ពស់សុវត្ថិភាពចំណីអាហារ ដោះស្រាយបណ្តឹងតវ៉ានានា ឱ្យស្របតាមយន្តការដោះស្រាយបណ្តឹងតវ៉ា។

ខ. គណៈកម្មការដឹកនាំនិងគ្រប់គ្រងចំពោះកិច្ចការអនុវត្តកម្មវិធីថ្នាក់ស្រុក ក្រុង និងអ្នកពាក់ព័ន្ធ ត្រូវ៖

- ផ្តល់វគ្គតម្រង់ទិសនិងបច្ចេកទេស ជូនដល់គ្រឹះស្ថានបឋមសិក្សាគោលដៅក្នុងករណីចាំបាច់ ដើម្បីធានាបានដល់ការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀន តាមគោលការណ៍ណែនាំប្រតិបត្តិប្រកបដោយប្រសិទ្ធភាព គណនេយ្យភាព និងបរិយាបន្ន។
- ផ្សព្វផ្សាយរាល់លិខិតបទដ្ឋានគតិយុត្ត ឯកសារណែនាំពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីទៅតាមគ្រឹះស្ថានបឋមសិក្សាគោលដៅ និងអ្នកពាក់ព័ន្ធឱ្យបានទូលំទូលាយនិងទាន់ពេលវេលា។
- កៀរគរធនធាន ថវិកាពីប្រភពស្របច្បាប់នៅតាមសហគមន៍ សប្បុរសជន និងវិស័យឯកជនពាក់ព័ន្ធនឹងការគាំទ្រនិងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបម្រើឱ្យការអនុវត្តកម្មវិធី។
- សម្របសម្រួលដល់រដ្ឋបាលឃុំ សង្កាត់ សហការជាមួយគ្រឹះស្ថានបឋមសិក្សាគោលដៅ ធ្វើការជ្រើសរើសអ្នកផ្គត់ផ្គង់ស្បៀងនិងចុងភៅតាមគោលការណ៍ណែនាំ និងលក្ខខណ្ឌនៃកិច្ចសន្យាជាធរមាន។
- ផ្ទៀងផ្ទាត់របាយការណ៍ស្តីពីការជ្រើសរើសអ្នកផ្គត់ផ្គង់ស្បៀងក្នុងប្រព័ន្ធព័ត៌មានគ្រប់គ្រងកម្មវិធី ដើម្បីធានាថាអ្នកទទួលជ័យលាភី និងទទួលសិទ្ធិជាអ្នកផ្គត់ផ្គង់ស្បៀង អនុលោមលក្ខណៈវិនិច្ឆ័យ និងលក្ខខណ្ឌមានចែងក្នុងបទដ្ឋានគតិយុត្តរបស់កម្មវិធី។
- ចូលរួមដោះស្រាយបញ្ហាប្រឈមនៃការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀន រាយការណ៍ជូនគណៈកម្មការដឹកនាំនិងគ្រប់គ្រងចំពោះកិច្ចការអនុវត្តកម្មវិធីថ្នាក់ខេត្ត និងអ្នកពាក់ព័ន្ធ។
- ត្រួតពិនិត្យការបញ្ចូលទិន្នន័យស្បៀងនិងថវិកាក្នុងប្រព័ន្ធព័ត៌មានគ្រប់គ្រងកម្មវិធីរបស់គ្រឹះស្ថានបឋមសិក្សាគោលដៅទៀងទាត់រៀងរាល់ខែ ដើម្បីជាមូលដ្ឋានធ្វើរបាយការណ៍បានទាន់ពេល។
- សម្របសម្រួលជាមួយគ្រឹះស្ថានបឋមសិក្សាគោលដៅ ពីតម្រូវការថវិកាទិញស្បៀង និងប្រាក់ឧបត្ថម្ភចុងភៅប្រចាំត្រីមាស និងរៀបចំសំណើថវិកាជូនទៅមន្ទីរអប់រំ យុវជន និងកីឡាឱ្យទាន់ពេលវេលា ដើម្បីធានាថាមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចបើកផ្តល់សាច់ប្រាក់ បានទាន់ពេលវេលា។
- ចូលរួមប្រជុំប្រចាំត្រីមាសនៅថ្នាក់ខេត្ត ជាមួយគណៈកម្មការដឹកនាំនិងគ្រប់គ្រងចំពោះកិច្ចការអនុវត្តកម្មវិធីថ្នាក់ខេត្ត ដើម្បីពិនិត្យលើវឌ្ឍនភាព បញ្ហាប្រឈម ស្វែងរកដំណោះស្រាយ និងទទួលយកអនុសាសន៍របស់ថ្នាក់ដឹកនាំ ដើម្បីលើកទិសដៅអនុវត្តនៅត្រីមាសបន្ទាប់។

គ. គណៈកម្មការដឹកនាំនិងគ្រប់គ្រងចំពោះកិច្ចការអនុវត្តកម្មវិធីថ្នាក់ខេត្ត និងអ្នកពាក់ព័ន្ធ ត្រូវៈ

- ដឹកនាំប្រជុំប្រចាំត្រីមាស ប្រចាំឆ្នាំ និងប្រជុំវិសាមញ្ញ ជាមួយគណៈកម្មការដឹកនាំនិងគ្រប់គ្រងចំពោះកិច្ចការអនុវត្តកម្មវិធីថ្នាក់ក្រុង ស្រុក ពិនិត្យលើវឌ្ឍនភាព រកដំណោះស្រាយ និងលើកទិសដៅបន្ត។
- ផ្តល់វគ្គតម្រង់ទិស និងបច្ចេកទេសជូនគ្រឹះស្ថានបឋមសិក្សាគោលដៅ ក្នុងករណីចាំបាច់ ដើម្បីធានាបានការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀន ដោយគោរពតាមគោលការណ៍ណែនាំប្រតិបត្តិប្រកបដោយប្រសិទ្ធភាព គណនេយ្យភាព និងបរិយាបន្ន។
- ផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត ឯកសារណែនាំពាក់ព័ន្ធការអនុវត្តកម្មវិធីជូនរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ គ្រឹះស្ថានបឋមសិក្សាគោលដៅ និងអ្នកពាក់ព័ន្ធឱ្យបានទូលំទូលាយទាន់ពេលវេលា។
- ចូលរួមនិងគាំទ្រដល់ការកៀរគរធនធានពីប្រភពស្របច្បាប់នៅតាមសហគមន៍ ពីសប្បុរសជន និងវិស័យឯកជន គាំទ្រដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងបម្រើឱ្យកម្មវិធីបានកាន់តែល្អប្រសើរ។
- ពិនិត្យ បូកសរុបរបាយការណ៍រីកចម្រើន និងរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាស ជូនអភិបាលនៃគណៈអភិបាលខេត្ត គណៈកម្មការដឹកនាំនិងគ្រប់គ្រងការអនុវត្តកម្មវិធីថ្នាក់ជាតិ តាមកាលកំណត់។

## ៣.៣ ការតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងរបាយការណ៍

គណៈកម្មការដឹកនាំនិងគ្រប់គ្រងចំពោះកិច្ចការអនុវត្តកម្មវិធីថ្នាក់ខេត្ត ស្រុក ក្រុង និងឃុំ សង្កាត់ ត្រូវៈ

- ធ្វើផែនការចុះពិនិត្យតាមដានជួយគាំទ្រដល់គ្រឹះស្ថានបឋមសិក្សាគោលដៅឱ្យបំពេញភារកិច្ចប្រកបដោយប្រសិទ្ធភាព ដោយប្រើប្រាស់ឧបករណ៍ពិនិត្យតាមដាន និងប្រព័ន្ធកូបុងរបស់កម្មវិធី។
- ចូលរួមពិនិត្យតាមដាន វាយតម្លៃ និងដោះស្រាយបណ្តឹងតវ៉ានានា ទាក់ទងនឹងការអនុវត្តកម្មវិធី និងផ្សព្វផ្សាយជូនអ្នកពាក់ព័ន្ធ ស្របតាមយន្តការដោះស្រាយបណ្តឹងតវ៉ា។
- ពិនិត្យឡើងវិញទិន្នន័យបញ្ចូលរួចដោយគ្រឹះស្ថានបឋមសិក្សាគោលដៅ ក្នុងប្រព័ន្ធព័ត៌មានគ្រប់គ្រងកម្មវិធី ឱ្យប្រាកដថាទិន្នន័យគ្រប់គ្រាន់និងត្រឹមត្រូវ រួចរាយការណ៍ជូនក្រសួងអប់រំ យុវជន និងកីឡា (នាយកដ្ឋានបឋមសិក្សា) តាមពេលវេលាកំណត់។
- ត្រួតពិនិត្យរបាយការណ៍របស់គ្រឹះស្ថានបឋមសិក្សាគោលដៅ ផ្តោតលើការប្រើប្រាស់ថវិកា ស្បៀងតាមដំណាក់កាល។ ស្ថិតិសិស្ស ត្រូវផ្ទៀងផ្ទាត់ឱ្យមានសង្គតិភាពជាមួយការិយាល័យផែនការនិងគ្រប់គ្រងជំនួយ នៃមន្ទីរអប់រំ យុវជន និងកីឡា តាមដំណាក់កាល ដូចខាងក្រោមៈ

❖ <u>របាយការណ៍ត្រីមាសទី១ (ចាប់ពីថ្ងៃទី០១ ខែវិច្ឆិកា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤)</u>

- ពីថ្ងៃទី៥ ដល់ថ្ងៃទី១០ ខែមករា ឆ្នាំ២០២៥ សាលាបឋមសិក្សា ត្រូវបញ្ជូនរបាយការណ៍មកការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាអប់រំ យុវជន និងកីឡាខេត្ត
- ពីថ្ងៃទី១០ ដល់ថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៥ ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ត្រូវបញ្ជូនរបាយការណ៍មកមន្ទីរអប់រំ យុវជន និងកីឡាខេត្ត
- មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ត្រូវបញ្ជូនរបាយការណ៍មកនាយកដ្ឋានបឋមសិក្សាយ៉ាងយូរត្រឹមថ្ងៃទី២០ ខែមករា ឆ្នាំ២០២៥។

❖ <u>របាយការណ៍ត្រីមាសទី២(ចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៥)</u>

- ពីថ្ងៃទី៥ ដល់ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៥ សាលាបឋមសិក្សា ត្រូវបញ្ជូនរបាយការណ៍មកការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក
- ពីថ្ងៃទី១០ ដល់ថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២៥ ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាល ក្រុង

ស្រុក ត្រូវបញ្ជូនរបាយការណ៍មកមន្ទីរអប់រំ យុវជន និងកីឡាខេត្ត

- មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ត្រូវបញ្ជូនរបាយការណ៍មកនាយកដ្ឋានបឋមសិក្សាយ៉ាងយូរ ត្រឹមថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៥។

❖ <u>របាយការណ៍ត្រីមាសទី៣ (ចាប់ពីថ្ងៃទី០១ ខែមេសា ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៥)</u>

- ពីថ្ងៃទី០៥ ដល់ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៥ សាលាបឋមសិក្សា ត្រូវបញ្ជូនរបាយការណ៍មកការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក
- ពីថ្ងៃទី១០ ដល់ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៥ ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ត្រូវបញ្ជូនរបាយការណ៍មកមន្ទីរអប់រំ យុវជន និងកីឡាខេត្ត
- មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ត្រូវបញ្ជូនរបាយការណ៍មកនាយកដ្ឋានបឋមសិក្សាយ៉ាងយូរត្រឹមថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៥។

❖ <u>របាយការណ៍ត្រីមាសទី៤ (ចាប់ពីថ្ងៃទី០១ ខែកក្កដា ដល់ថ្ងៃទី៣១ ខែកញ្ញា ឆ្នាំ២០២៥)</u>

- ពីថ្ងៃទី០៥ ដល់ថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៥ សាលាបឋមសិក្សា ត្រូវបញ្ជូនរបាយការណ៍មកការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក
- ពីថ្ងៃទី១០ ដល់ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២៥ ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ត្រូវបញ្ជូនរបាយការណ៍មកមន្ទីរអប់រំ យុវជន និងកីឡាខេត្ត
- មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ត្រូវបញ្ជូនរបាយការណ៍មកនាយកដ្ឋានបឋមសិក្សាយ៉ាងយូរត្រឹមថ្ងៃទី២០ ខែតុលា ឆ្នាំ២០២៥។

ទទួលបានសេចក្តីណែនាំនេះ មន្ទីរអប់រំ យុវជន និងកីឡាខេត្តពាក់ព័ន្ធ ត្រូវណែនាំ និងផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់រដ្ឋបាលក្រុង ស្រុក រដ្ឋបាលឃុំ សង្កាត់ និងសាលាបឋមសិក្សាគោលដៅ ព្រមទាំងអ្នកពាក់ព័ន្ធ ឱ្យអនុវត្តប្រកបដោយប្រសិទ្ធភាព និងការទទួលខុសត្រូវខ្ពស់។

ថ្ងៃពុធ ១៣កើត ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

- គ្រប់រដ្ឋបាលខេត្តពាក់ព័ន្ធ
- គ្រប់អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន និងអគ្គាធិការដ្ឋាន
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី "ដើម្បីជូនជ្រាបជាព័ត៌មាន"
- កាលប្បវត្តិ.ឯកសារ នាយកដ្ឋានបឋមសិក្សា